ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.៨១៣.០១៩...០១.ឈស.ញភណពត៌.៤៨

*ថ្ងៃ ចន្ទ ៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩*

# សេចក្ដីប្រកាសព័ត៌មាន ស្ដីពី
# កិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំរវាងធនាគារជាតិនៃកម្ពុជា និងធនាគាររដ្ឋវៀតណាម

ថ្ងៃចន្ទ ៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩

នាព្រឹកថ្ងៃចន្ទ ៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំជាមួយធនាគាររដ្ឋវៀតណាម ក្រោមអធិបតីភាព ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង ឯកឧត្តម Le Minh Hung ទេសាភិបាល ធនាគាររដ្ឋវៀតណាម។

កិច្ចប្រជុំទ្វេភាគីត្រូវបានរៀបចំឡើង ក្នុងគោលបំណងរឹតចំណងកិច្ចសហប្រតិបត្តិការ និង ទំនាក់ទំនងជាមិត្តភាពរវាងធនាគារកណ្ដាលទាំងពីរ។ ភាគីទាំងពីរបានពិភាក្សាផ្លាស់ប្ដូរយោបល់ទៅលើ ៖ i/- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងវិស័យធនាគារ និង ii/- វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគី។

ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើននៃកិច្ចសហប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជានិងធនាគាររដ្ឋវៀតណាម ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យធនាគារ និងសេដ្ឋកិច្ចនៃប្រទេសទាំងពីរ។ នាពេលកន្លងមក ធនាគារកណ្ដាលទាំងពីរបានផ្លាស់ប្ដូរបទពិសោធន៍ទៅវិញទៅមកទៅលើការងារចម្បងៗ សំដៅពង្រឹងប្រសិទ្ធភាពការងារស្នូលរបស់ធនាគារកណ្ដាល ព្រមទាំងពង្រឹងសមាហរណកម្មវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលគាំទ្រដល់ពាណិជ្ជកម្មនិងវិនិយោគរបស់ប្រទេសទាំងពីរ។

ដើម្បីបន្តពង្រឹងនិងពង្រីកសហប្រតិបត្តិការទ្វេភាគីល្អ ដែលជាប្រយោជន៍ដល់វិស័យធនាគារ ក៏ដូចជាសេដ្ឋកិច្ចនៃប្រទេសទាំងពីរ ធនាគារកណ្ដាលទាំងពីរបានឯកភាព i/-បន្តផ្លាស់ប្ដូរបទពិសោធន៍ទៅវិញទៅមក ជាពិសេសទៅលើការលើកកម្ពស់ការទូទាត់ជារូបិយវត្ថុជាតិសម្រាប់ពាណិជ្ជកម្មឆ្លងដែនតាមរយៈប្រព័ន្ធធនាគារ, ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ, ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម, និងការត្រួតពិនិត្យធនាគារ និង ii/- សហការអភិវឌ្ឍធនធានមនុស្សតាមរយៈការផ្ដល់អាហារូបករណ៍ដល់មន្ត្រីធនាគារជាតិនៃកម្ពុជា។

កិច្ចប្រជុំនេះបានបញ្ចប់ទៅដោយជោគជ័យនិងប្រកបដោយផ្លែផ្កា ក្រោមបរិយាកាសសប្បាយរីករាយ ភាតរភាពនិងស្និទ្ធស្នាលបំផុត។

ទំនាក់ទំនង៖
ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
ទូរស័ព្ទ៖ ០២៣ ៩៩០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh